# ខ្មែរបាត់សាមគ្គី ខ្មែររងទុក្ខ

១. ខ្មែរបាត់សាមគ្គី ខ្មែររងទុក្ខ    ខ្មែរនឹងបាត់ស្រុក ព្រោះយួនសៀម
ខ្មែរនឹងរលត់ បើខ្មែរស្ងៀម    ខ្មែរនឹងរហាម ដូចចម្ប៉ា ។

២. ខ្មែរបាត់សាមគ្គី ខ្មែររងកម្ម    បើខ្មែរប្រេះស្រាំ មិនផ្សះផ្សា
មិនលើកតំកើង ជាតិសាសនា    នោះជាតិខេមរា ខ្មែររលត់ ។

៣. ខ្មែរបាត់សាមគ្គី ខ្មែរនឹងស្លាយ    បីដូចបាត់កាយ រលាយផុត
ទឹកភ្នែកនឹងហូរ ដោយតក់ស្លុត    ព្រោះជាតិរលត់ ដីបាត់បង់ ។

៤. ខ្មែរបាត់សាមគ្គី យួន សៀម សើច    បញ្ចើចបញ្ចើច អោយខ្មែរល្ងង់
ដឹកនាំប្រទេស អោយបាត់បង់    អោយលិច អោយលង់ ព្រោះតណ្ហា ។

៥. តណ្ហា នៃបុណ្យ សក្តិ អំណាច    ប្រៀបដូចបិសាច មកប្រហារ
អោយខ្មែរបែកបាក់ ក្រុមគ្រួសារ    ដូចរាម សីតា ព្រាត់ព្រោះរាពណ៍ ។

៦. តណ្ហា នៃបុណ្យ សក្តិ អំណាច    សាហាវពន់ពេក គ្មានអ្វីប្រៀប
អោយកូនចៅខ្មែរ ភ្លេចរបៀប    ទំនាមទំលាប់ កេរ្តិ៍ដូនតា ។

៧. តណ្ហា នៃបុណ្យ សក្តិ អំណាច    សាហាវពន់ពេក ប្រៀបដូចខ្លា
ភ្លេចអស់គុណ ទោស គ្មានធមិ អារ្យ    បំពេញអាត្មា តាមចំណង់ ។

៨. យួនសៀមសប្បាយ ក្អាកក្អាយពេក    ព្រោះឃើញខ្មែរបែក ខ្មែរបាត់បង់
អាណិតកូនចៅ ខ្មែររហង់    ដែលកំពុងរស់ រងទឹកភ្នែក ។

៩. បើខ្មែរអាណិត ខ្មែរដូចគ្នា    នេះជាវេលា មិនចាំស្អែក
ត្រូវរួមសាមគ្គី ឈប់បែបែក    នោះទើបទឹកភ្នែក ខ្មែរលែងហូរ ។

**ដោយ សួន សេរីរដ្ឋា (ដែនដីសេរីភាព)**
អាមេរិក ខែមេសា ទី ១៤ ឆ្នាំ ២០០៦